ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមត្រីប្រាក្នុងស្រះ



រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**
**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម** (ARDB)

ខែកុម្ភៈ ឆ្នាំ២០២៥

023 220 811
023 220 810
012 847 387
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

## មាតិកា


**១-សេចក្តីផ្តើម**.................................................1
**២-លក្ខណៈជីវសាស្ត្ររបស់ត្រីប្រា**.................................................1
**៣-បច្ចេកទេសចិញ្ចឹមត្រីប្រាក្នុងស្រះ**.................................................2
៣.១. ការជ្រើសរើសទីតាំង និងការរៀបចំស្រះ.................................................2
៣.២. ការដាក់កូនត្រីពូជចិញ្ចឹម.................................................2
៣.៣. ចំណី និងការផ្តល់ចំណី.................................................3
៣.៤. ការគ្រប់គ្រង និងថែទាំ.................................................4
៣.៥. ការបង្ការជំងឺ.................................................4
៣.៦. ការប្រមូលផល.................................................5
**៤-គម្រោងអាជីវកម្មចិញ្ចឹមត្រីប្រា**.................................................5
៤-១-គម្រោងចិញ្ចឹម.................................................5
៤-២-ការវិភាគសេដ្ឋកិច្ចការចិញ្ចឹមក្នុង១វគ្គ.................................................6
៤-៣-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់.................................................7
៤-៤-ការវិភាគលើខ្សែច្រវាក់តម្លៃ.................................................7
**៥-ហានិភ័យ-បញ្ហាប្រឈម**.................................................8
**៦-សេចក្តីសន្និដ្ឋាន**.................................................9
**ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ**.................................................9

## ១-សេចក្តីផ្តើម

ត្រីប្រា ជាប្រភេទត្រីទឹកសាបដែលប្រជាកសិករនិយមចូលចិត្តចិញ្ចឹមយ៉ាងទូលំទូលាយជាលក្ខណៈគ្រួសារតាមបែបពាក់កណ្តាលប្រពលវប្បកម្ម និងប្រពលវប្បកម្មទាំងនៅក្នុងស្រះ និងក្នុងបែ សម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងការនាំចេញ។ ត្រីប្រាស៊ីចំណីចម្រុះអាចចិញ្ចឹមដោយផ្តល់ចំណីគ្រាប់សម្រេចពីរោងចក្រ និងចំណីផ្សំដោយខ្លួនឯង។ កសិករអាចដាក់ចិញ្ចឹមត្រីប្រាបានពេញមួយឆ្នាំ ដោយរកទិញកូនត្រីប្រាពូជដែលបានបង្កាត់ភ្ញាស់សិប្បនិម្មិតពីស្ថានីយ៍ឬកសិដ្ឋានបង្កាត់ភ្ញាស់កូនត្រីពូជក្នុងស្រុក ដែលកត្តាគុណភាពនៃកូនត្រីពូជគឺជាការសំខាន់សម្រាប់កសិករចិញ្ចឹមផងដែរ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ តម្លៃចំណីសម្រេចពីរោងចក្រ និងធាតុចូលសម្រាប់ផលិតចំណីដោយខ្លួនឯងបានកើនឡើង ធ្វើឱ្យថ្លៃដើមផលិតត្រីប្រាសាច់ក៏បានកើនឡើង និងបង្ករផលលំបាកដល់កសិករចិញ្ចឹមត្រីប្រាយ៉ាងខ្លាំង។ ខាងក្រោមនេះ ជាគម្រោងអាជីវកម្មចិញ្ចឹមត្រីប្រាដែលបានដកស្រង់ចេញពីបទពិសោធន៍ជាក់ស្តែងរបស់បណ្តុំកសិករចិញ្ចឹមត្រីប្រាផ្ទាល់ ដើម្បីទុកជាមូលដ្ឋានសម្រាប់អ្នកចិញ្ចឹមសិក្សាស្វែងយល់បង្កើនចំណេះដឹងបន្ថែមទៀត។

## ២-លក្ខណៈជីវសាស្ត្ររបស់ត្រីប្រា

ត្រីប្រា ជាប្រភេទត្រីរំអិលដែលដងខ្លួនគ្របដណ្តប់ដោយស្បែក រស់នៅក្នុងមជ្ឈដ្ឋានទឹកសាប និងចូលចិត្តបន្លាស់ទីពីតំបន់មួយទៅតំបន់មួយនៅក្នុងប្រទេសនៃតំបន់អាស៊ី ជាពិសេសនៅតាមបណ្តោយដងទន្លេមេគង្គនៃប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ត្រីប្រាមានចរិកស៊ីចំណីចម្រុះ មានដូចជាប្រភេទសត្វ ប្លង់តុងដែលមានទំហំតូច ស្លែរ ឬសរុក្ខជាតិ បន្លែទឹក បង្គា ក្តាម ខ្យង សត្វល្អិត និងត្រីតូចៗជាដើម។ ក្នុងស្រះចិញ្ចឹម ត្រីប្រាមានសមត្ថភាពសម្របខ្លួនជាមួយនឹងចំណីជាច្រើនប្រភេទផ្សំពីកន្ទក់ ចុងអង្ករ កាកសំណល់ផ្ទះបាយ បន្លែ និងផ្តល់ចំណីគ្រាប់សម្រេចពីក្រុមហ៊ុន។ ត្រីប្រា មានការលូតលាស់លឿនគួរសមដោយចិញ្ចឹមក្នុងស្រះ១ឆ្នាំមានទម្ងន់ចន្លោះពី ១-១.៥គីឡូក្រាម/ក្បាល។ ត្រីមានភាពធន់នឹងជម្ងឺ អាចរស់បានក្នុងលក្ខខណ្ឌដែលមានកម្រិត pH តូចជាង៥ ធន់បានជាមួយកម្រិតសីតុណ្ហភាពដល់ទៅ ៣៩អង្សាសេ និងកម្រិតអុកស៊ីសែនរលាយក្នុងទឹកទាបជាងត្រីកាបស៣ដង ដោយសារត្រីប្រាអាចដកដង្ហើមបានតាមរយៈប្លោកខ្យល់ និងស្បែក។



**ត្រីប្រាធំ (Pangasius hypophthalmus)**

(Striped Catfish)

## ៣-បច្ចេកទេសចិញ្ចឹមត្រីប្រាក្នុងស្រះ ÷

បច្ចេកទេសសំខាន់ៗនៃការចិញ្ចឹមត្រីប្រាក្នុងស្រះតាមបែបពាក់កណ្ដាលប្រពលវប្បកម្មដែលជាចំណេះដឹងបន្ថែមដល់ប្រជាកសិករកម្ពុជា រួមមានដូចខាងក្រោម÷

### ៣.១. ការជ្រើសរើសទីតាំង និងការរៀបចំស្រះ÷

- ជ្រើសរើសស្រះដែលនៅជិតប្រភពទឹកស្អាត និងមិនប៉ះពាល់ដោយទឹកជំនន់
- ជាតំបន់ដែលគ្មានសារធាតុពុល ថ្នាំសម្លាប់សត្វល្អិត និងការបំពុលសរីរាង្គ និងថ្នាំគីមី
- នៅទីវាល មានពន្លឺថ្ងៃចាំងចូលគ្រប់គ្រាន់ (គ្មានដើមឈើធំៗនៅជុំវិញ)
- ស្រះគួរមានទំហំចាប់ពី ៥០០ម៉ែ$^{២}$ឡើងទៅ ជម្រៅចាប់ពី ១.៥-៣ម៉ែត្រ មាត់ស្រះមាំ ខ្ពស់ជាងកម្រិតទឹកខ្ពស់បំផុតក្នុងឆ្នាំ។
- ស្រះចាស់ត្រូវសម្អាតសំរាម និងកាកសំណល់ផ្សេងៗចេញពីក្នុងស្រះ
- បូមភក់បាតស្រះឱ្យសល់ត្រឹម ០.២-០.៣ម៉ែត្រ និងទុកហាលស្រះពី ៥-៧ថ្ងៃ
- បាចកំបោរកម្ចាត់ពពួកសត្វកាច មេរោគ និងបង្កើនគុណភាពទឹកជាមួយបរិមាណកំបោរចន្លោះពី ១០ ទៅ ១៥ គ.ក/១០០ម៉ែ$^{២}$ និងទុករយៈពេលពី ២-៥ថ្ងៃ។
- ហ៊ុមសំណាញ់ព័ទ្ធជុំវិញស្រះ ដើម្បីការពារត្រីខាងក្រៅចូលក្នុងស្រះ ការពារកូនត្រីខាងក្នុងចេញ
- ដំណាក់កាលដំបូងបញ្ចូលទឹកក្នុងស្រះជម្រៅទឹកពី ១ ទៅ ១.២ម៉ែត្រ និងបន្ទាប់មកបញ្ចូលបន្ថែមដល់ជម្រៅពី ១.៥ ទៅ ២ម៉ែត្រ។




### ៣.២. ការដាក់កូនត្រីពូជចិញ្ចឹម÷

កូនត្រីពូជគួរទិញពីស្ថានីយបង្កាត់ភ្ញាស់ឬកសិដ្ឋានផ្សាំដែលអាចទុកចិត្តបាន និងមិនធ្លាប់មានផ្ទុះជំងឺ។ ចំណុចសំខាន់ៗក្នុងការជ្រើសរើសកូនត្រីពូជល្អរួមមានដូចខាងក្រោម÷

- ផលិតក្នុងស្ថានីយដែលមានការកត់ត្រាច្បាស់លាស់ មេបាពូជល្អ មានកេរ្តិ៍ឈ្មោះល្អ និងរៀបចំបានស្អាត។
- មានទំហំធំចន្លោះពី ១០-១៥ សង់ទីម៉ែត្រ/ក្បាល ឬទម្ងន់ចន្លោះពី ៨០-១០០ក្រាម/ក្បាល
- មានទំហំប៉ុនៗគ្នា ឬប្រហាក់ប្រហែលគ្នា

- មានសុខភាពល្អ ៖ មានសាច់ មាំមួន ពណ៌សម្បុរស្រស់ថ្លា រហ័សរហួន
- គ្មានរបួសស្នាមឬដំបៅលើដងខ្លួន មានរូបរាងស្អាត គ្មានដុំពកឬប៉ោង
- ដង់ស៊ីតេដាក់កូនត្រីពូជចិញ្ចឹម ចន្លោះពី ១៥ ទៅ ២០ក្បាល/ម$^{២}$

កូនត្រីគួរលែងនៅពេលមេឃស្រឡះ សីតុណ្ហភាពត្រជាក់។ កុំលែងកូនត្រីនៅពេលមេឃមានភ្លៀង ពីព្រោះទឹកភ្លៀងមានជាតិអាស៊ីតនៅស្រទាប់លើនៃផ្ទៃទឹកក្នុងស្រះអាចធ្វើឱ្យត្រីងាប់បាន។ មុននឹងលែងកូនត្រី ត្រូវដាក់ថង់ត្រីត្រាំក្នុងស្រះរយៈពេល ១០-២០នាទី ដើម្បីធ្វើឱ្យសីតុណ្ហភាពខាងក្រៅ និងក្នុងថង់ប្រហាក់ប្រហែលគ្នា និងបន្ថយការនឿយហត់របស់ត្រី។ បន្ទាប់មកស្រាយមាត់ថង់ និងបាចទឹកពីខាងក្រៅចូលទៅក្នុងថង់បន្តិចម្តងៗ ឱ្យកូនត្រីហែលចេញតាមសម្រួល។ មិនត្រូវយកកូនត្រីទៅចាក់ចូលស្រះភ្លាមៗទាំងបង្ខំនោះទេ ពីព្រោះទឹកក្នុងស្រះ និងក្នុងថង់មានសីតុណ្ហភាពខុសគ្នា ដែលកូនត្រីមិនអាចធន់នឹងការប្រែប្រួលសីតុណ្ហភាពយ៉ាងឆាប់រហ័សនោះទេ អាចធ្វើឱ្យត្រីខ្សោយឬងាប់បាន។





**៣.៣. ចំណី និងការផ្តល់ចំណី៖**

បរិមាណចំណីគ្រប់គ្រាន់ កម្រិតប្រូតេអ៊ីនសមស្រប ពេលវេលាផ្តល់ចំណីត្រឹមត្រូវ និងទីតាំងផ្តល់ចំណីច្បាស់លាស់គឺជាកត្តាសំខាន់ធ្វើឱ្យត្រីលូតលាស់ធំធាត់លឿននិងទទួលបានទិន្នផលស្របតាមផែនការកំណត់។ ចំណីដែលត្រូវផ្តល់ឱ្យត្រីស៊ីប្រចាំថ្ងៃត្រូវមានការសិក្សា និងគណនាច្បាស់លាស់ស្របតាមទម្ងន់ត្រីនៅក្នុងស្រះ។ ចំណីគ្រាប់ពីរោងចក្រត្រូវបានផ្តល់នៅដើមខែដំបូងក្នុងបរិមាណ ៣-៤%នៃទម្ងន់ត្រី និងមានកម្រិតប្រូតេអ៊ីន ៣០%។ បន្ទាប់មកផ្តល់ចំណីផ្សំដោយខ្លួនឯងពី កន្ទក់ម៉ត់ ៥០% បន្លែបៃតង ២០% និងម្សៅត្រី ៣០% ក្នុងបរិមាណពី ៥-៨%នៃទម្ងន់ត្រី ដោយផ្តល់ឱ្យត្រីស៊ី ១-២ដង/ថ្ងៃ ដែលមេគុណចំណីជាមធ្យមពី ២.៥-៣.៥គ.ក អាចផលិតបានត្រីសាច់១គ.ក។





### ៣.៤. ការគ្រប់គ្រង និងការថែទាំ៖

ត្រូវពិនិត្យតាមសកម្មភាពត្រី ការស៊ីចំណីរបស់កូនត្រី និងស្ថានភាពនៃការប្រែប្រួលសីតុណ្ហភាពជាប្រចាំ ដើម្បីកំណត់បាននូវការប្រើប្រាស់ចំណីបានសមស្រប និងមានប្រសិទ្ធភាពខ្ពស់។ ពេលឃើញកូនត្រីឡើងមកផ្ទៃទឹកខាងខុសធម្មតា ត្រូវប្រញាប់កំណត់ពីមូលហេតុ និងដោះស្រាយបានទាន់ពេលវេលា។ ត្រូវធ្វើសំណាកកូនត្រីម្តងក្នុង១ខែ ដោយចាប់ត្រីចន្លោះពី ២៥-៥០ក្បាល ដើម្បីកំណត់ទម្ងន់កូនត្រីជាមធ្យមក្នុង១ក្បាល និងវាយតម្លៃការលូតលាស់។ ការពិនិត្យគុណភាពទឹកគួរធ្វើឡើងម្តងក្នុង១សប្តាហ៍ លើកម្រិត pH អុកស៊ីសែនរលាយក្នុងទឹក និងកម្រិតអាម៉ូញាក់ ដើម្បីគ្រប់គ្រងហានិភ័យកើតឡើងជាយថាហេតុ និងអាចដោះស្រាយបានទាន់ពេលវេលា។ ចាប់ពីខែទី៣ ត្រូវមានការផ្លាស់ប្តូរទឹក១ដង/ខែ ក្នុងបរិមាណពី ៣០-៥០% ដោយបូមទឹកពីបាតស្រះ និងបូមទឹកបញ្ចូលស្រះវិញដំណាលគ្នា ដើម្បីគ្រប់គ្រងសីតុណ្ហភាពទឹកក្នុងស្រះ និងទឹកបញ្ចូលថ្មីកុំឱ្យមានការប្រែប្រួលខ្លាំងពេកដែលអាចប៉ះពាល់ដល់សុខភាពត្រី។






### ៣.៥. ការបង្ការជំងឺ៖

ពេលត្រីកើតជំងឺមានការលំបាកក្នុងការព្យាបាល និងងាយរងនូវការបាត់បង់ខ្ពស់ ហេតុនេះកសិករត្រូវយកចិត្តទុកដាក់ការពារកុំឱ្យត្រីកើតជំងឺ ដោយគួរពង្រឹងសុខភាពត្រីតាមរយៈការបន្ថែមវីតាមីនសេ (Vitamin-C) លាយជាមួយចំណីពី ៧-១០ថ្ងៃម្តង ដើម្បីជួយពង្រឹងប្រព័ន្ធការពារ និងប្រព័ន្ធរំលាយអាហាររបស់ត្រី បង្កើនការស្រូបយកសារធាតុចិញ្ចឹមពីចំណីបានខ្ពស់។ ការកម្ចាត់បាក់តារី និងប៉ារ៉ាស៊ីតនៅក្នុងខ្លួនត្រីគួរធ្វើឡើង១ខែម្តង ដោយលាយជាមួយចំណីឱ្យត្រីស៊ីរយៈពេល ២-៣ថ្ងៃ។ ទន្ទឹមនឹងនេះ ការកម្ចាត់ពពួកបាក់តេរី និងប៉ារ៉ាស៊ីតនៅក្នុងទឹកស្រះចិញ្ចឹមត្រីគួធ្វើឡើងជាប្រចាំ តាមរយៈការប្តូរទឹកពី ២០-៥០% ឬអាចប្រើកំបោរសប្រមាណ ២០០គ.ក/១០ ០០០ម៉$^{៣}$ ទឹកក្នុងស្រះដើម្បីរក្សាលំនឹងសារធាតុចិញ្ចឹម។





### ៣.៦. ការប្រមូលផល÷

បន្ទាប់ពីចិញ្ចឹមបានរយៈពេលពី ៨-១០ខែ ត្រីមានទម្ងន់ពី០.៨-១.២គ.ក/ក្បាល គឺអាចប្រមូលផលត្រីមានទំហំធំស្របតាមតម្រូវការទីផ្សារនិងរក្សាទុកត្រីដែលមានទំហំតូចចិញ្ចឹមបន្ត។ ត្រូវផ្អាកផ្តល់ចំណីពី ២-៣ថ្ងៃឬតិចបំផុត១ថ្ងៃមុនពេលប្រមូលផល។ ការប្រមូលផលជ្រើសរើសទំហំត្រីត្រូវប្រើអួនអូសសន្សឹមៗ មិនត្រូវអូសយកត្រីច្រើនពេកទេ ពីព្រោះអាចបណ្តាលឱ្យត្រីរងរបួស ខ្សោយនិងងាប់បាន។ ការជ្រើសត្រីត្រូវធ្វើឱ្យបានលឿន និងមានសម្ភារៈស្តុកត្រីឱ្យបានត្រឹមត្រូវទើបមិនប៉ះពាល់ដល់គុណភាពសាច់ត្រី។





## ៤-គម្រោងអាជីវកម្មចិញ្ចឹមត្រីប្រា÷

### ៤-១-គម្រោងចិញ្ចឹម (បទពិសោធន៍របស់កសិករចិញ្ចឹមត្រី នៅខេត្តសៀមរាប)

- ទំហំស្រះចិញ្ចឹម ÷ ៥,៤០០ម៉ែ៣ (បណ្តោយ ៥០ម៉ ទទឹង ៣៦ម៉ ជម្រៅ ៣ម៉)
- ចំនួនកូនត្រីពូជ/វគ្គ ÷ ២០,០០០ ក្បាល
- រយៈពេលចិញ្ចឹម ÷ ៨ខែ/វគ្គ
- ចំណីផ្តល់ឱ្យត្រីស៊ី ÷ ចំណីគ្រាប់ពីរោងចក្រ និងត្រីនុយ
- សមាមាត្រចំណី (FCR) ÷ ជាមធ្យម ២.៧២ : ១
- អត្រាបាត់បង់ ÷ មធ្យម ១៥% (អាស្រ័យលើសុខភាពកូនពូជ និងការថែទាំ)
- ទិន្នផល ÷ ជាមធ្យម ១១,៩០០គ.ក/វគ្គ ( ជាមធ្យម ០.៧គ.ក/ក្បាល)
- ទីផ្សារ ÷ លក់ឱ្យឈ្មួញបោះដុំនៅខេត្តសៀមរាប និងកំពង់ធំ
- តម្លៃទីផ្សារ ÷ លក់បោះដុំតម្លៃជាមធ្យម ៤,៥០០រៀល/ គ.ក (តម្លៃចន្លោះខែកក្កដា ដល់ខែ តុលា)
- តម្រូវការទុន ÷ សម្រាប់ចាប់ផ្តើមអាជីវកម្មដំបូង ដោយរៀបចំស្រះ និងបំពាក់សម្ភារៈ ត្រូវចំណាយដើមទុនដូចខាងក្រោម÷

| **ទុនវិនិយោគសម្រាប់ជីកស្រះ និងបំពាក់សម្ភារៈ (រៀល)** | **ទុនសម្រាប់ដំណើរការចិញ្ចឹម (រៀល)** | **ទឹកប្រាក់សរុបសម្រាប់ចាប់ផ្តើមអាជីវកម្មដំបូង (រៀល)** |
|---|---|---|
| **30,960,000** | **41,310,000** | **72,270,000** |

### ៤-២-ការវិភាគសេដ្ឋកិច្ចការចិញ្ចឹមក្នុង១វគ្គ÷

ការចិញ្ចឹមត្រីប្រា ដោយដាក់កូនត្រីចំនួន **២០,០០០ក្បាល** ចិញ្ចឹមរយៈពេល ០៨ខែ (ក្នុង១វគ្គ) មាន អត្រាបាត់បង់ជាមធ្យម ១៥% និងក្រោយកាត់រំលស់ឧបករណ៍-សម្ភារៈ រួមមានដូចខាងក្រោម÷

| ល.រ | មុខចំណាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ/ឯកត្តា (៛) | តម្លៃសរុប (៛) | ចំនួនវគ្គរំលស់ | តម្លៃសរុប/វគ្គ (៛) |
|---|---|---|---|---|---|---|---|
| **ចំណូលពីការលក់ត្រី** | | | | | | | |
| 1 | ចំណូលពីការលក់ត្រី | គ.ក | 11,900 | 4,500 | 53,550,000 | | **53,550,000** |
| **ចំណាយសរុប (ក + ខ)** | | | | | **72,270,000** | | **42,549,833** |
| **ក-ការចំណាយប្រែប្រួល** | | | | | **41,310,000** | | **41,310,000** |
| 1 | កូនត្រីពូជ | ក្បាល | 20,000 | 120 | 2,400,000 | | 2,400,000 |
| 2 | កំបោរស | គ.ក | 180 | 1,500 | 270,000 | | 270,000 |
| 3 | ចំណីសម្រេចរោងចក្រ | គ.ក | 250 | 4,000 | 1,000,000 | | 1,000,000 |
| 4 | ចំណីផ្សំខ្លួនឯង | គ.ក | 30,240 | 1,000 | 30,240,000 | | 30,240,000 |
| 5 | ប្រេងសាំងឬម៉ាស៊ូត/វគ្គ | ខែ | 8 | 400,000 | 3,200,000 | | 3,200,000 |
| 6 | ថ្នាំការពារ និងព្យាបាល | វគ្គ | 1 | 1,000,000 | 1,000,000 | | 1,000,000 |
| 7 | កម្លាំងពលកម្ម/វគ្គ(២០%) | ខែ | 8 | 400,000 | 3,200,000 | | 3,200,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **30,960,000** | | **1,239,833** |
| 1 | ជីកស្រះ | ម៉ែ៣ | 5,400 | 5,000 | 27,000,000 | 40 | 675,000 |
| 2 | ម៉ាស៊ីនបូមទឹក | គ្រឿង | 1 | 1,200,000 | 1,200,000 | 10 | 120,000 |
| 3 | ក្បាលកិនចំណីត្រី | គ្រឿង | 1 | 1,200,000 | 1,200,000 | 10 | 120,000 |
| 4 | ទុយោបូមទឹកទន់ (៥០ម/ដុំ) | ដុំ | 4 | 60,000 | 240,000 | 10 | 24,000 |
| 5 | ស្បៃហ៊ុំស្រះ និងបង្គោលឈើ | ដុំ | 6 | 50,000 | 300,000 | 4 | 75,000 |
| 6 | រៀបចំកន្លែងដាក់ចំណី | កន្លែង | 1 | 150,000 | 150,000 | 6 | 25,000 |
| 7 | សំណាញ់បង់ត្រី | វង់ | 1 | 150,000 | 150,000 | 4 | 37,500 |
| 8 | ជញ្ជីងអេឡិចត្រូនិចនិងប៉ុង | គ្រឿង | 2 | 260,000 | 520,000 | 4 | 130,000 |
| 9 | តាកាដាក់ត្រី ចានដែក ធុង... | ឈុត | 1 | 200,000 | 200,000 | 6 | 33,333 |
| **ចំណេញសរុប** | | | | | | | **11,000,167** |
| ចំណាយថ្លៃដើមក្នុងការចិញ្ចឹមត្រីក្នុង ១ គ.ក | | | | | | | **3,576** |
| ចំណេញពីការផលិតត្រីសាច់ក្នុង ១ គ.ក | | | | | | | **924** |

### ៤-៣-ការវិភាគលទ្ធផលដោយផ្អែកលើនិន្នាកាតម្លៃលក់÷

តាមបទពិសោធន៍របស់កសិករដែលក្រុមការងារបានសិក្សាផ្ទាល់ ការចិញ្ចឹមត្រីប្រានៅក្នុងស្រះមានអត្រាបាត់បង់ជាមធ្យម ១៥% អាស្រ័យលើសុខភាពកូនត្រីពូជ ការគ្រប់គ្រង-ថែទាំ។ ក្នុងករណីកូនត្រីពូជមានសុខភាពមិនល្អ ការផ្តល់ចំណីមិនបានត្រឹមត្រូវ និងការគ្រប់គ្រង-ថែទាំមិនច្បាស់លាស់ ប៉ះពាល់ដល់សុខភាពត្រី នាំឱ្យអត្រាបាត់បង់ខ្ពស់ និងផលចំណេញធ្លាក់ចុះ។ ដោយឡែកតម្លៃត្រីនៅលើទីផ្សារមានការប្រែប្រួលក្នុងចន្លោះពី ៤,០០០-៥,០០០៛/គ.ក។ បើអត្រាបាត់បង់ដល់២៥% និងតម្លៃលក់ចេញបានត្រឹម ៤,០០០៛/គ.ក នេះអ្នកចិញ្ចឹមប្រឈមនិងការខាតបង់។ ប៉ុន្តែបើកសិករគ្រប់គ្រងបានល្អ អត្រាបាត់បង់ត្រឹម ១៥% ទោះបីតម្លៃលក់ចេញត្រឹម ៤,០០០៛/គ.ក ក៏នៅទទួលបានផលចំណេញ។

**តារាងវិភាគលទ្ធផលដោយផ្អែកលើអត្រាបាត់បង់ និងតម្លៃលក់មានដូចខាងក្រោម÷**

| ទិន្នផលទទួលបាន (គ.ក) | តម្លៃលក់ចេញ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់អំពីទិន្នផល |
|---|---|---|---|---|---|
| 11,900 | 4,000 | 47,600,000 | 42,549,833 | 5,050,167 | ករណីអត្រាបាត់បង់១៥% |
| | 4,500 | 53,550,000 | 42,549,833 | 11,000,167 | |
| | 5,000 | 59,500,000 | 42,549,833 | 16,950,167 | |
| 11,200 | 4,000 | 44,800,000 | 42,549,833 | 2,250,167 | ករណីអត្រាបាត់បង់២០% |
| | 4,500 | 50,400,000 | 42,549,833 | 7,850,167 | |
| | 5,000 | 56,000,000 | 42,549,833 | 13,450,167 | |
| 10,500 | 4,000 | 42,000,000 | 42,549,833 | (549,833) | ករណីអត្រាបាត់បង់២៥% |
| | 4,500 | 47,250,000 | 42,549,833 | 4,700,167 | |
| | 5,000 | 52,500,000 | 42,549,833 | 9,950,167 | |

### ៤-៤-ការវិភាគលើខ្សែច្រវាក់តម្លៃ÷

**កសិករ** ÷ ករណីលក់ទៅឈ្មួញកណ្តាលបោះដុំក្នុងតម្លៃមធ្យម ៤,៥០០៛/គ.ក តម្លៃថ្លៃដើមផលិត ៣,៥៧៦៛/គ.ក កសិករអាចចំណេញបាន ៩២៤៛/គ.ក ។

**ឈ្មួញកណ្តាល**÷ លក់ទៅអ្នកលក់រាយក្នុងផ្សារបានតម្លៃ ៦,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ ៥០០៛/គ.ក អាចចំណេញបាន ១,០០០៛/គ.ក

**អ្នកលក់រាយ** ÷ លក់បានតម្លៃ ១០,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ និងថែរក្សា ១៥០០៛/គ.ក អាចចំណេញបាន ២,៥០០៛/គ.ក ។

## ៥-ហានិភ័យ និងបញ្ហាប្រឈម

តាមការសិក្សាផ្ទាល់ជាមួយកសិករចិញ្ចឹមត្រីប្រាក្នុងស្រះនៅខេត្តសៀមរាប កសិករដែលមានបំណងចិញ្ចឹមត្រីប្រាត្រូវស្វែងយល់ និងរកវិធីគ្រប់គ្រងនូវហានិភ័យ និងបញ្ហាប្រឈមចម្បងៗមួយចំនួនទៅលើអាជីវកម្មរួមមានដូចខាងក្រោម÷

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាហានិភ័យ | វិធានការក្នុងការគ្រប់គ្រងហានិភ័យ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | កូនត្រីពូជមិនល្អ សុខភាពខ្សោយ ទំហំកូនត្រីមិនស្មើគ្នា បណ្តាលឱ្យការលូតលាស់មិនស្មើគ្នា ។ | - ស្វែងយល់ពីប្រវត្តិកសិដ្ឋានផលិតកូនត្រីឱ្យបានច្បាស់លាស់អំពីមេពូជ និងភាពស្មោះត្រង់។<br>- ត្រូវជ្រើសរើសកូនត្រីមានទំហំស្មើគ្នា សុខភាពល្អ មិនមានរបួសស្នាម។ |
| | | ផ្តល់ចំណីមិនបានត្រឹមត្រូវ ធ្វើឱ្យកូនត្រីមានសុខភាពខ្សោយ ធំធាត់យឺត មានជំងឺ អត្រាបាត់បង់ខ្ពស់ និងប្រឈមការខាតបង់។ | - ផ្តល់ចំណីឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ទាំងចំណីសម្រេចពីរោងចក្រ និងចំណីផ្សំដោយខ្លួនឯងដែលមានតម្លៃសមរម្យ។<br>- គ្រប់គ្រងការផ្តល់ចំណីមិនលើស និងមិនខ្វះ |
| | | ការគ្រប់គ្រង និងថែទាំមិនបានដិតដល់ នឹងបង្ករឱ្យត្រីមានសុខភាពមិនល្អ កើតជំងឺ ប៉ះពាល់ដល់ការលូតលាស់ និងមានការបាត់បង់ខ្ពស់។ | - ត្រូវត្រួតពិនិត្យគុណភាពទឹក និងមានការផ្លាស់ប្តូរទឹកពី ២០-៥០% ជាប្រចាំ។<br>- ផ្តល់ចំណីគ្រប់គ្រាន់តាមបច្ចេកទេស មិនលើសមិនខ្វះ។<br>- មានកម្មវិធីបង្ការជំងឺ ដើម្បីពង្រឹងប្រព័ន្ធការពារ និងរំលាយអាហាររបស់ត្រី រក្សាលំនឹងសារធាតុចិញ្ចឹម កម្ចាត់បាក់តេរី និងប៉ារ៉ាស៊ីត។ |
| ២ | ហានិភ័យទីផ្សារ | ត្រីប្រាមានតម្រូវការទីផ្សារខ្ពស់ ប៉ុន្តែតម្លៃប្រែប្រួលមិនទៀងទាត់ មានភាពប្រថុយប្រថានខ្ពស់។ | - ចងក្រងជាបណ្តុំដើម្បីភ្ជាប់ខ្សែច្រវាក់តម្លៃទីផ្សារ អាចចែករំលែកចំណេះដឹងនិងព័ត៌មានគ្នាទៅវិញទៅមក។<br>- ទំនាក់ទំនងជាមួយឈ្មួញប្រមូលទិញបានច្រើនកន្លែង ច្រើនប្រភេទ ដើម្បីមានជម្រើសច្រើនក្នុងការសម្រេចចិត្តលក់។ |
| ៣ | ហានិភ័យហិរញ្ញវត្ថុ | ការចិញ្ចឹមទ្រង់ទ្រាយធំ អាជីវកម្មត្រូវមានទុនបម្រុងទុក សម្រាប់ទិញចំណី និងវត្ថុធាតុដើមក្នុងការផលិតចំណី ដែលមានការចំណាយខ្ពស់។ | - ទោះជាការចិញ្ចឹមទ្រង់ទ្រាយតូចឬធំ ផែនការអាជីវកម្មត្រូវមានជាចាំបាច់។<br>- មានផែនការអាជីវកម្មច្បាស់លាស់ |

## ៦-សេចក្តីសន្និដ្ឋាន

ទោះបីអាជីវកម្មចិញ្ចឹមត្រីប្រា មានបញ្ហាប្រឈមពីតម្លៃនៅលើទីផ្សារមានការប្រែប្រួលមិនទៀងទាត់ ប៉ុន្តែត្រីប្រាជាប្រភេទត្រីដែលមានតម្រូវការទីផ្សារខ្ពស់។ ការចិញ្ចឹមត្រីប្រាមិនសូវមានការលំបាកនោះទេ បើសិនជាអ្នកចិញ្ចឹមបានសិក្សាស្វែងយល់ពីបច្ចេកទេសឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមអាជីវកម្ម។ លើសពីនេះអ្នកចិញ្ចឹមត្រូវមានផែនការអាជីវកម្ម ចេះកែច្នៃឬភាពច្នៃប្រឌិតលើការផ្តល់ចំណី មានការថែទាំ និងគ្រប់គ្រងស្រះចិញ្ចឹមឱ្យបានត្រឹមត្រូវសមស្របតាមបទដ្ឋានបច្ចេកទេស។ ថ្លៃដើមផលិតត្រីប្រាជាមធ្យមគឺ ៣,៥៧៦រៀល/គ.ក បើលក់ត្រីបានត្រឹមតម្លៃ ៤,០០០រៀល/គ.ក ជាមួយនឹងអត្រាបាត់បង់ ២០% អ្នកចិញ្ចឹមនៅអាចទទួលបានចំណេញតិចតួច ប៉ុន្តែប្រសិនជាអាត្រាបាត់បង់កើនដល់២៥% នោះអាជីវកម្មនឹងខាតបង់។ អ្នកចិញ្ចឹមត្រូវយកចិត្តទុកដាក់លើការជ្រើសរើសពូជមានគុណភាពល្អ ផ្តល់ចំណីផ្សំដោយខ្លួនឯងដែលមានតម្លៃទាបសមរម្យ ថែទាំ និងគ្រប់គ្រង់ស្រះចិញ្ចឹមត្រីឱ្យបានត្រឹមត្រូវ ដើម្បីកាត់បន្ថយអត្រាបាត់បង់ និងថ្លៃដើមផលិតទាប។

**ប្រភព និងឯកសារសម្រាប់សិក្សាស្រាវជ្រាវ៖**

១- បណ្តុំកសិករចិញ្ចឹមត្រីប្រា នៅខេត្តសៀមរាប

២- បច្ចេកទេសចិញ្ចឹមត្រីប្រា នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

- *https://elibrary.maff.gov.kh/*
- គេហទំព័រ YouTube ÷ បច្ចេកទេសចិញ្ចឹមត្រីប្រា
- *https://agro.gov.vn/vn/tID11762_Nuoi-ca-tra-bang-thuc-an-tu-che.html*
- *http://biospring.com.vn/kien-thuc-chuyen-nganh/thuc-danh-cho-ca-tra-giong-tang-truong-nhanh.html*
- *https://www.mekongfishmarket.com/vi/danh-gia-tin-tuc/moi-truong-song-va-thuc-an-cua-ca-tra-va-ca-basa*